ធ៧-០១០-០០១ ស.រ.ណ

# សារាចរណែនាំ
# ស្តីពី
# ការកំណត់ចំណាត់ថ្នាក់វិនិយោគ

ដើម្បីអនុវត្តច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ ឱ្យមានភាពរលូនស្របតាមការវិវត្តន៍នៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាណែនាំអំពី ចំណាត់ថ្នាក់វិនិយោគ សម្រាប់ភាគទុនិកមានឥទ្ធិពល ដែលជាគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ និងកាតព្វកិច្ចពាក់ព័ន្ធនានារបស់គ្រឹះស្ថានធនាគារ ដែលទទួលបានអាជ្ញាប័ណ្ណប្រកបមុខរបរធនាគារនៅព្រះរាជាណាចក្រកម្ពុជាដូចតទៅ៖

១- ភាគទុនិកមានឥទ្ធិពលទាំងនេះត្រូវទទួលបានការវាយតម្លៃពីភ្នាក់ងារចាត់ថ្នាក់អន្តរជាតិ (International Rating Agencies) យ៉ាងតិចចំនួនមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិបីគឺ Moody’s Asia Pacific, Standard & Poor’s Corporation និង Fitch ។ ចំណាត់ថ្នាក់វិនិយោគនេះសំដៅលើចំណាត់ថ្នាក់រយៈពេលវែង (Long Term Rating) ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ណាមួយដូចខាងក្រោម៖

| **Moody’s Asia Pacific** | **Standard & Poor’s Corporation** | **Fitch** | Grade |
|---|---|---|---|
| **Long Term Rating** | **Long Term Rating** | **Long Term Rating** | |
| Aaa | AAA | AAA | Prime |
| Aa1 | AA+ | AA+ | High Grade |
| Aa2 | AA | AA | |
| Aa3 | AA- | AA- | |
| A1 | A+ | A+ | Upper Medium Grade |
| A2 | A | A | |
| A3 | A- | A- | |
| Baa1 | BBB+ | BBB+ | Lower Medium Grade |
| Baa2 | BBB | BBB | |
| Baa3 | BBB- | BBB- | |

២- ធនាគារពាណិជ្ជ ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការវាយតម្លៃ “ចំណាត់ថ្នាក់វិនិយោគ” ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០ (ហាសិបពាន់លាន) រៀល។ ធនាគារពាណិជ្ជ ដែលពុំមានភាគទុនិកមានឥទ្ធិពល ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល។ ធនាគារពាណិជ្ជដែល

បង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល ទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬ ភាគទុនិកមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៣- ធនាគារឯកទេស ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយ ជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល។ ធនាគារឯកទេស ដែលពុំមានភាគទុនិកមានឥទ្ធិពលជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ (សាមសិបពាន់លាន)រៀល។ ធនាគារឯកទេស ដែលបង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាចំនួន ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀលទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬ ភាគទុនិកមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៤- គ្រឹះស្ថានធនាគារត្រូវផ្តល់លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់វិនិយោគ (Confirmation of the Rating) របស់ភាគទុនិកមានឥទ្ធិពលរបស់ខ្លួន ដែលចេញដោយភ្នាក់ងារចាត់ថ្នាក់អន្តរជាតិមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិទាំងបីខាងលើមកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់រៀងរាល់ដើមឆមាសនីមួយៗ។ លើសពីនេះទៀត គ្រឹះស្ថានធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ប្រសិនបើភ្នាក់ងារវាយតម្លៃបន្ថយការធ្វើចំណាត់ថ្នាក់ ភាគទុនិកមានឥទ្ធិពលក្រោមចំណាត់ថ្នាក់វិនិយោគ។

៥- ភាគទុនិកមានឥទ្ធិពលត្រូវចេញលិខិតធានាបង្កើនដើមទុន នៅពេលចំណាត់ថ្នាក់របស់ខ្លួនធ្លាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ឬនៅពេលដែលធនាគារជាតិនៃកម្ពុជា តម្រូវឱ្យបង្កើនដើមទុន ដោយផ្អែកលើការវាយតម្លៃអំពីស្ថានភាពហានិភ័យរបស់ធនាគារ។ លិខិតធានាបង្កើនដើមទុននេះត្រូវមានចែងពីការសន្យា ដែលមិនអាចកែប្រែបាន (Irrevocable) ចំពោះធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់ដើមទុនបន្ថែមនៅក្នុងរវាង ៥ (ប្រាំ) ថ្ងៃធ្វើការ និងបញ្ចប់ការរៀបចំសំណុំឯកសារបង្កើនដើមទុននៅក្នុងរវាង ៣០ ថ្ងៃ ចាប់ពីថ្ងៃផ្ទេរដើមទុន។ លិខិតធានាបង្កើនដើមទុន ត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើនដើមទុនរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬធនាគារមេ ដែលជាភាគទុនិក ដែលមានឥទ្ធិពល និងត្រូវបានជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម។

៦- ការសន្យាផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន ដូចមាននៅក្នុងចំណុច ៤ និង ៥ ខាងលើ ត្រូវមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីភាគទុនិកមានឥទ្ធិពល ។ ឯកសារដែលនឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជារួមមាន៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ការសន្យាផ្តល់សេចក្តីបញ្ជាក់ ការសន្យារាយការណ៍ និង លិខិតធានាបង្កើនដើមទុន)
- លិខិតជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើមអំពីការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ឱ្យមានការសន្យា ផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន និង
- លិខិតធានាបង្កើនដើមទុនរបស់ភាគទុនិកមានឥទ្ធិពល។

៧- ក្នុងករណីដែលគ្រឹះស្ថានធនាគារស្វែងរកជំនួយគាំទ្រពីធនាគារបរទេស គ្រឹះស្ថានធនាគារនោះត្រូវផ្តល់ព័ត៌មាន ដូចខាងក្រោមមកធនាគារជាតិនៃកម្ពុជា ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០៖

- អនុស្សារណៈយោគយល់ ឬលិខិតស្ម័គ្រចិត្តចូលរួមវិនិយោគ ដោយមិនអាចកែប្រែបាន ដោយមានបញ្ជាក់ពីចំនួនភាគហ៊ុន ដែលមានបំណងកាន់កាប់ និងផែនការយុទ្ធសាស្ត្រ ស្តីពី ការវិនិយោគនៅ

កម្ពុជា ដែលឆ្លុះបញ្ចាំងនូវការប្តេជ្ញារយៈពេលវែង និងចំណាប់អារម្មណ៍ក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជា។

- ច្បាប់ចម្លងស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលធនាគារបរទេស និងលិខិតជូនដំណឹងដល់អាជ្ញាធរត្រួតពិនិត្យប្រទេសដើម អំពីគោលបំណងវិនិយោគរបស់ធនាគារបរទេសនោះ។
- សេចក្តីប្រកាសរបស់ធនាគារបរទេសអំពីការយល់ដឹងនូវការទទួលខុសត្រូវរបស់ខ្លួន ជាភាគទុនិកមានឥទ្ធិពល ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ហើយសន្យាអនុវត្តតាមឱ្យបានពេញលេញ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**